**សេចក្តីប្រកាសព័ត៌មាន**

សន្និសីទសារព័ត៌មានស្តីពី ការដាក់លិខិតរួមគ្នារបស់អង្គការសង្គមស៊ីវិល ស្នើសុំកិច្ចអន្តរាគមន៍ពី សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

លើសេចក្តីព្រាងច្បាប់សិទ្ធិទទួលព័ត៌មាន ទៅខុទ្ទកាល័យនាយករដ្ឋមន្ត្រី

ភ្នំពេញថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២ - អង្គការសង្គមស៊ីវិលចំនួន៣៣នឹងរៀបចំធ្វើសន្និសីទសារព័ត៌មានមួយនៅបរិវេណខុទ្ទកាល័យនាយករដ្ឋមន្ត្រី នៅថ្ងៃទី**១៦ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង ៩:០០ព្រឹក** ស្តីពី ការស្នើសុំឱ្យពន្លឿនសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន ។

គោលបំណងសំខាន់នៃការដាក់លិខិត គឺដើម្បីស្នើសុំកិច្ចអន្តរាគមន៍ដ៏ខ្ពង់ខ្ពស់ពី សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី ដើម្បីបញ្ចប់ដំណើរការនៃការតាក់តែងសេចក្តីព្រាងច្បាប់ស្តីពី **"សិទ្ធិទទួលព័ត៌មាន"** ដោយមានការដាក់បញ្ចូលធាតុចូលពីអង្គការសង្គមស៊ីវិល និងដាក់ជូនទៅរដ្ឋសភាដើម្បីពិភាក្សា និងអនុម័តឱ្យបានឆាប់រហ័ស ។

អង្គការសង្គមស៊ីវិល បាននិងកំពុងចូលរួមយ៉ាងសកម្មក្នុងការធានាឱ្យសម្រេចបាននូវកម្មវិធីកំណែទម្រង់របស់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសទៅលើការលើកកម្ពស់ **"សិទ្ធិទទួលព័ត៌មាន"** ដើម្បីចូលរួមការលើកកម្ពស់សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យសម្រាប់ការអភិវឌ្ឍលើគ្រប់វិស័យ។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**

**លោក ឡាំ សុជាតិ** នាយកប្រតិបត្តិនៃវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API)

ទូរសព្ទ៖ ០១២ ៧១៨ ៦១១/០៩៨ ៧១៨ ៦១២

អ៊ីមែល៖ socheat.lam@apiinstitute.org

**លោក ណុប វី** នាយកប្រតិបត្តិនៃសមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា)

ទូរសព្ទ៖ ០១២ ៥១៩ ២៦១

អ៊ីមែល៖ ed@camboja.net

**លោក អ៊ិត សូធឿត** នាយកនៃនាយកដ្ឋានប្រព័ន្ធផ្សព្វផ្សាយនៃមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM)

ទូរសព្ទ៖ ០១២ ៨១៩ ៥៤៥

អ៊ីមែល៖ isothoeuth@vodhotnews.com

**កញ្ញា ស្រី សុធាវី** នាយិកានៃអង្គការក្រុមការងារដើម្បីដោះស្រាយទំនាស់ (ACT)

ទូរសព្ទ៖ ០១៧ ៩៩ ០៣ ៧១

អ៊ីមែល៖ director@act-kh.org